
ផ្កា
ស្រពោន
T.cheat

## ២

រាត្រីស្ងាត់ ។ ពន្លឺអគ្គិសនីដែលបំភ្លឺផ្លូវថ្នាលចោលរន្ទះពណ៌មាសទៅក្នុងទឹកពណ៌ខ្មៅនៃស្ទឹងសង្កែ ដែលហូរត្រកួញខ្ទាញ់ ។

ម៉ោង ១០យប់ហើយ ។ នៅត្រើយខាងកើត ចង្រិតយំមួយៗ ហើយយូរៗម្តង មានរ៉ឺម៉កររត់រ៉ោឆ្លងស្ពានដែក ដឹកនាំអ្នកដែលត្រឡប់មកពីអាស្រ័យបបរសាមចូក នៅទីផ្សារវិលទៅកាន់ភូមិឋានវិញ ។

នៅតាមមាត់កំពង់ ដែលមានជួរដើមអំពិលធំត្រឈឹងត្រឈៃជាលំអ ពួកក្មេងកំលោះ តែងមកប្រជុំគ្នានៅអង្គុយលើរានតូចៗ ដើម្បីយករំហើយ ហើយនិយាយកំសាន្តរទូៗ ។

នៅភូមិវត្តពោធិក្នុង ត្រង់កំពង់ចំឡងឆ្ពោះទៅសាលារៀន ក៏មានកូនរានមួយជ្រកក្រោមអំពិលផ្អែមមួយដើមដែរ ។ តែដោយភូមិនេះ ពុំមានក្មេងកំលោះដូចភូមិឯទៀត កូនរាននេះក៏នៅទំនេរ ឥតមាននរណាមកអ៊ូអែឡើយ ។

នៅយប់ដែលយើងដំណាលរឿងនេះ បើប្រសិនជាមានអ្នកដំណើរណាមួយមកឈប់ អង្គុយលេងនៅលើរានអំពិលផ្អែម គេនឹងឮសំឡេងនារីពីរោះក្រអៅ អណ្តែតចេញមកល្ហើយៗ ពីផ្ទះមួយដែលមានព្រឹក្សាដុះគ្របជុំវិញ ។ ឱសំឡេងអើយ ដែលរសាត់មកតាមវាយោជាមួយនឹងពិដោរ ក្រអូបត្រជាក់នៃផ្កាម្លិះ និងកុលាប ! ឱសំឡេងអើយថ្លាដូចចរណៃ គួឲ្យពិសម័យដល់ម្ចាស់សំឡេងនេះពន់ប្រមាណ ។

អ្នកដំណើរ កាលបើបានស្តាប់សំឡេងនេះហើយ ក៏មិនងាយនឹងដកខ្លួនចេញពីរាននោះរួចទេ ព្រោះកម្រណាស់ នឹងមានសំណាងបានស្តាប់សំឡេង ដែលមានឱជារសយ៉ាងនេះឡើយ !

បើប្រសិនជាអ្នកដំណើរនោះ ឆ្ពោះភក្ត្រមើលត្រង់ទៅខាងកើតក៏នឹងឃើញពន្លឺចង្កៀងចាំងចេញ តាមប្រឡោះស្លឹករុក្ខជាតិ ហើយនឹងឃើញមាន ផ្លូវមួយក្រាលឥដ្ឋ នាំដំហានទៅដល់ជណ្តើរនៃ គេហដ្ឋានមួយដែលសង់ជារោងដោយ ដំបូលប្រក់ក្បឿងជញ្ជាំងក្តារឥតលាបថ្នាំ ដែលប្រែសំបុរទៅជាប្រផេះ ដោយត្រូវភ្លៀង និងត្រូវថ្ងៃ ។ នៅយ៉ខាងមុខដែលភ្ជាប់ និងរានហាល មានសង់ហោណាំង ១ ប្រក់ស័ង្កសីនិងមានបន្ទះឈើ ជាចរឹងព័ទ្ធពីខាងមុខ ។ នៅទីនេះមានក្តារជើមួយធ្វើពីខ្លឹមក្រកោះខ្មៅរលើប ។ អ្នកម្ចាស់ផ្ទះមុន និងបិទទ្វារដេក តែងមកសន្ទឹងយករំហើយនៅកន្លែងនេះ ។

គេហដ្ឋានដ៏មានរបងស្អុកស្អម្កតែងស្ងាត់ជ្រងំ ដោយមានតែមនុស្សស្រីបីនាក់ឋិតនៅ ។

យាយនួនមានអាយុ ៥០ឆ្នាំប្លាយហើយសក់ស្កូវមួយៗ ហើយកោខ្ចី ដោយគាត់កាន់ឧបោសថមិនដែលខានឡើយ ។ នេត្រគាត់ដែលមានពន្លឺថ្លាយង់ ហើយជ្រកនៅក្នុងរង្វង់ព្រមទាំងរង្វង់ថ្ពាមមាំ យ៉ាងរឹងប៉ឹង សំដែងឲ្យយល់ថា ស្ត្រីនេះជាអ្នកចិត្តរឹងរូសមានះណាស់ ។ បើគំនិតគាត់បែរទៅចាប់អ្វីហើយ គ្មាននរណាងាយនឹងដកគំនិតនោះយកមកបានទេ ។ តាំងតែប្តីគាត់ស្លាប់ចោលទៅកាលណា គាត់លះបង់ជំនួញជួញប្រែទាំងអស់ ។ គាត់ខំតែការពារ ធនធានដែលមានទាំងប៉ុន្មានទុកឲ្យកូនស្រីគាត់ ដែលគាត់មានសេចក្តីប្រតិព័ទ្ធ លើសលប់ជាងអ្វីៗទាំងអស់ ។

នាងវិធារី ជាបុត្រីយាយនួន ។ នាងចំរើនវ័យបាន ១៧ឆ្នាំហើយ ។ នាងមានរូបឆោមលោមពណ៌ស្រស់ចំប្រប់រាងរៀវទន់ភ្លន់ មុខមូលវែង ហើយទុកសក់ប្រះស្មាខ្មៅញាប់ ។ នាងជាអ្នកសុភាព ស្តាប់ដំបូន្មានម្តាយនាងជាដរាប ។ កាលដែលនៅពីតូច នាងបានទៅរៀនអក្សរនៅសាលាវត្តពោធិវាល ។ គ្រូនាងតែងសរសើរពី ប្រាជ្ញារបស់នាង ។ លុះនាងបានពេញជំទង់ហើយ ម្តាយនាងឲ្យឈប់រៀន ។ ដូច្នេះនាងក៏នៅកាន់កាប់ការតែក្នុងផ្ទះទៅ តែបើមានពេលទំនេរនាងតែងទៅសិក្សារៀនភាសាសៀម និងរៀនប៉ាក់ផុលជាមួយគ្រូស្រីម្នាក់ ដែលនៅជិតផ្ទះនាង ។ មិនបានប៉ុន្មានខែក្រោយមក នាងក៏ចេះ

មើលសៀវភៅរឿងសៀមបាន ។ ឯបង្អួចផ្ទះ ស្រោមខ្នើយសោត ក៏មានក្បាច់ភ្ញីលំអ ឡើងដោយស្នាដៃនាងក្នុងការអញ្ចុល ។

អ្នកផ្ទះទីបី គឺយាយផៃ ។ គាត់បាននៅបំរើគ្រួសារយាយនួននេះ តាំងតែពីមុនសម័យដែលនាងវិធារី មកចាប់បដិសន្ធិ ។ គាត់មានអាយុចាស់ជាងយាយនួនទៅទៀត ស្បែកគាត់ក៏សិងស្វិតជ្រីវ សក់គាត់ក៏សិងស្កូវស្ទើរគ្មានសល់មួយសរសៃទៅហើយ ។ នាងវិធារី តែងរាប់អានគាត់ដូចជាសាច់ញាតិពេញទី ។ មួយទៀត យាយផៃគាត់ក៏មិនចង់ដើរទៅណាឡើយ ព្រោះគាត់ធ្លាប់បីបមនាងវិធារី ហើយធ្លាប់ស្រឡាញ់តាំងតែពីកូនង៉ាមក ។ គាត់ហៅ យុវតីនេះថា នាងតូចៗ ដូច្នេះ ។

នៅយប់ដែលយើងពណ៌នានេះ យាយនួនគាត់មានកង្វល់ក្នុងចិត្ត ហើយគាត់បានបបួលកូនគាត់ ឲ្យមើលក្រាំងព្រះលក្ខិណាវង្សគ្រាន់កែអផ្សុក ។

នៅពេលនោះ ចង្កៀងចូបមួយអុជដាក់ចំរើនលើក្បាលដំណេកនៃនាងវិធារី ។ នារីនេះស្លៀកសំពត់ខ្មៅ ពាក់អាវព្រៃសាច់ម៉ដ្ឋពណ៌កុលាប ហើយបើកាលណានាងយារដៃឆ្វេង បើកសន្លឹកក្រាំងម្ដងៗ ឡើងចិញ្ចៀនពេជ្រទាំងគ្រាប់ត្បូងមួយ ដែលជាគ្រឿងលំអនៃដៃនាង ក៏ដេញភ្លើងភ្លឺព្រោងព្រាយ ។ នាងអានរឿងព្រះលក្ខិណាវង្សធ្វើបទបញ្ចេញសំឡេង មូលក្រអៅពិរោះឥតឧបមា ។ គឺសំឡេងនេះហើយ ដែលអ្នកដំណើរបានស្ដាប់ព្លល្ងើយៗ ពីផ្លូវមាត់កំពង់ ។

ពេលនេះយាយនួន មានមុខស្ងួត ដេកនៅស្ងៀមអែបនៅកៀនបុត្រីគាត់ ។ ឯភ្នែកគាត់សំឡឹងដោតពិតានខ្ទាប់ធ្វើឲ្យយល់ថា វិញ្ញាណស្ត្រីនេះអណ្ដែតអណ្ដូងទៅក្នុងគំនិតអ្វីមួយ ដែលមានសណ្ឋានកណ្ដាញ់ចាក់ស្រែះ ដូចអំបោះ ដែលសំផុរហើយរកដើម រកចុងមិនឃើញជាពុំខាន ។

ចំណែកយាយផៃវិញ គាត់អង្គុយត្របោមជង្គង់ ខ្នងផ្អែកនាជញ្ជាំង ហើយស្ដាប់ធ្វើមាត់ប្រហើរ ។ លុះមើលដល់ត្រង់ព្រះលក្ខិណាវង្ស ជឿតាមពាក្យក្លែងនាងយីស៊ុន

ហើយប្រើឲ្យពេជ្ឈឃាត យកចៅព្រាហ្មណ៍ទៅសំលាប់ យាយដៃគាត់ជូតទឹកភ្នែកយ៉ាងញឹកញាប់ ។ លុះដល់គេបណ្ដើរឲ្យនាងព្រាហ្មណ៍កេសរ ស្រែកអាក្រោសតាមផ្លូវ យាយដៃគាត់ខឹងខ្លាំងណាស់ទប់មិនបានក៏ស្ទុះក្រោកឈរឡើងហើយស្រែកថា :

អញថាហើយ ! ....ថាកុំ ឲ្យមកតាម ... ប្រុសឥឡូវតែយ៉ាងនេះឯង ! បានថ្មីចោលចាស់ ឥតពិគ្រោះពិចារណាទេ !

ឮសំដីនេះហើយ នាងវិធាវីដែលកំពុងជក់តាមរឿង ក៏បែរភក្ត្រមកមើលឃើញយាយដៃ គាត់ស្ទុះក្រញេងក្រញាងដូច្នោះ នាងក៏ញញឹមសើចបញ្ចេញធ្មេញថ្លាដូចផ្កាម្លិះ ហើយសួរទៅដោយសំដីផ្អែមថា :

- អីម៉េច ម៉ែដៃ !

ស្ត្រីនេះ កាលបើឮសំដីនេះហើយ ក៏ភ្ញាក់ភ្ញារដឹងខ្លួន ដូចគេទើបក្រោកពីដេក ។ នៅស្រឡាំងកាំងមួយសន្ទុះ ទើបឆ្លើយតបថា :

- អត់ទោសឲ្យខ្ញុំចុះនាងតូច ខ្ញុំខឹងណាស់ ខឹងនឹងមនុស្សដែលធ្វើការអ្វីមិនមានពិចារណា រករាក់ជ្រៅវែងឆ្ងាយសោះ ។

យាយនួន លុះឮវាចា យាយដៃថាដូច្នេះ ក៏ភ្ញាក់ខ្លួនព្រើតស្ទុះក្រោកអង្គុយឡើង ហើយនិយាយថា :

- អាវីកូន មើលប៉ុណ្ណឹងចុះ យប់ក្រៃលលួមរកដេករកពួនហើយ ។ កុំភ្លេចថាយើងត្រូវក្រោកពីព្រឹកនឹងរកធ្វើការធ្វើងារនឹងគេ ។

នាងវិធាវីឮហើយ ក៏មីម្នាក្រោកអង្គុយ យកដៃក្បិតសក់បិទក្រាំង ហើយកាន់ចង្កៀងចូលទៅខាងក្នុង ។ យាយដៃគាត់ក៏ជញ្ជូនប្រអប់ស្លា និងផ្ដិល ដែលនៅរាយខាងក្រៅដាក់ទៅខាងក្នុងផ្ទះដែរ ។

បន្តិចក្រោយមក គន្លឹះទ្វារក៏ស្រែកគ្រាំងៗ ។ នាងវិធាវីផ្លុំភ្លើងពន្លត់ ហើយប្រវាចូលទៅនិទ្រា ប្របនឹងមាតានាង ។